# ជំពូក ៩

# ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

## Environmental Management Plan

Draft

# ជំពូកទី ៩

## ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

### ៩.១ សេចក្តីផ្តើម

នៅក្នុងជំពូកនេះគឺរៀបរាប់អំពីផែនការគ្រប់គ្រងបរិស្ថាន( ផ.គ.ប) ដែលនឹងត្រូវអនុវត្តតាមដំណាក់កាលរបស់គំរោង ជាពិសេសក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិថែទាំគំរោង និងបញ្ចប់គំរោង។ គោលបំណងសំខាន់នៃផ.គ.បនេះគឺត្រួតពិនិត្យ តាមដាននូវការអនុវត្តនីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានថែងក្នុងជំពូកទី ៧ និង៨។

ការត្រួតពិនិត្យការអនុវត្តន៍ ផ.គ.ប របស់CHD នេះជាភារកិច្ចរបស់ក្រុមចំរុះដែលមានការចូលរួមពីការិយាល័យ . មន្ទីរ . ក្រសួងដែលពាក់ព័ន្ធដែលនឹងត្រូវបង្កើតឡើងដោយម្ចាស់គំរោងរួមជាមួយក្រសួងបរិស្ថាន។ ក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការការពារ បរិស្ថាននេះ និងក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងបរិស្ថាន ។

### ៩.២ សមាសភាពនៃក្រុមត្រួតពិនិត្យ និងការឃ្លាំមើលការអនុវត្តន៍វិធានការការពារបរិស្ថាន

សមាសភាពក្រុមការងារត្រួតពិនិត្យ និងឃ្លាំមើលលើគំរោងវារីអគ្គិសនីស្ទឹងអាតៃនេះមានដូចតទៅ :

**ក. ក្រុមការងារគណកម្មការអន្តរក្រសួង**

១- ក្រសួងបរិស្ថាន រួមមាន មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន, មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន, និងនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង

២- មន្ត្រីជំនាញតំណាងឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៣- មន្ត្រីជំនាញតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤- មន្ត្រីជំនាញតំណាងឱ្យក្រសួងធនធានទឹក និងឧតុនិយម

៥- មន្ត្រីជំនាញតំណាងឱ្យក្រសួងរៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី

៦- មន្ត្រីជំនាញតំណាងឱ្យក្រសួងទេសចរណ៍

៧- មន្ត្រីជំនាញតំណាងឱ្យក្រសួងសាធារណការ និង ដឹកជញ្ជូន

៨- មន្ត្រីជំនាញតំណាងឱ្យក្រសួងកសិកម្ម

៩- មន្ត្រីជំនាញតំណាងឱ្យរដ្ឋបាលព្រៃឈើ

១០- មន្ត្រីជំនាញតំណាងឱ្យរដ្ឋបាលជលផល

១១- អ្នកតំណាងក្រុមហ៊ុន ។

**ខ. ក្រុមការងារអនុគណៈកម្មការខេត្ត**

១- មន្ត្រីជំនាញតំណាងឱ្យមន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់

២- មន្ត្រីជំនាញតំណាងឱ្យមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តពោធិ៍សាត់

៣- មន្ត្រីជំនាញតំណាងឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់

៤- មន្ត្រីជំនាញតំណាងឱ្យមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់

Draft

៥- មន្ត្រីជំនាញតំណាងឱ្យមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់

៦- មន្ត្រីជំនាញតំណាងឱ្យមន្ទីរទេសចរណ៍ ខេត្តពោធិ៍សាត់

៧- មន្ត្រីជំនាញតំណាងឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់

៨- មន្ត្រីជំនាញតំណាងឱ្យខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តពោធិ៍សាត់

៩- មន្ត្រីជំនាញតំណាងឱ្យខណ្ឌរដ្ឋបាលជលផល ខេត្តពោធិ៍សាត់

១០- មន្ត្រីជំនាញតំណាងឱ្យមន្ទីរសាធារណការ ខេត្តពោធិ៍សាត់

១១- អាជ្ញាធរដែនដី (ភូមិ ឃុំ/សង្កាត់ ស្រុក ក្រុង/ខេត្ត)

១២- អ្នកតំណាងក្រុមហ៊ុន ។

សមាសភាពក្រុមខាងលើមានតួនាទីពិនិត្យតាមដានដោយផ្ទាល់ និងដោយប្រយោល **ដើម្បីជួយ**តំរែតំរង់ និងកែលំអរាល់ការខ្វះខាតរបស់ក្រុមហ៊ុនក្នុងការអនុវត្តវិធានការណ៍ការពារបរិស្ថានរបស់គំរោង ។

<u>**បញ្ជាក់:**</u> សមាសភាពមន្ត្រីទាំងអស់នេះនឹងត្រូវផ្តល់តួនាទី និងមុខងារក្រោមការចង្អុលបង្ហាញពី**ក្រសួង**បរិស្ថាន ។

## ៩.៣ វិធានការណ៍សំខាន់ៗសំរាប់ការពារបរិស្ថាន

យោងតាមអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងយោង**តាម**លទ្ធផលនៃការសិក្សាស្តីពីការវាយតំលៃ ហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមដែលបង្កឡើងដោយសារសកម្មភាពនៅ**គ្រប់**ដំណាក់កាលរបស់គំរោងដូចបានរៀបរាប់ នៅក្នុងជំពូកទី៧ និងជំពូកទី៨ដែលម្ចាស់គំរោងនឹងរៀបចំកំណត់នូវវិធានការ**សំខាន់ៗ**មួយចំនួនសំរាប់ធ្វើការទប់ស្កាត់និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដើម្បីធានាបានការគ្រប់គ្រងធនធានបរិ**ស្ថាន**តំបន់នោះដោយប្រសិទ្ធិភាពស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថានព្រមទាំងធានាឱ្យគំរោងអភិវឌ្ឍន៍ប្រកប**ដោយ**ស្ថេរភាពដែលក្នុងនោះរួមមាន (ចំណុចសំខាន់ៗដែលត្រូវសរសេររបាយការណ៍ជូនក្រសួងបរិស្ថាន):

1 ការរៀបចំផ្នែក ឬ ក្រុមទទួលខុសត្រូវសំរាប់ការអនុវត្តផែនការការងារ ។

2 ការកំណត់ពេលវេលាធ្វើការងារឱ្យច្បាស់លាស់ ក្នុងកិច្ចការការពារបរិស្ថាន ។

3 ការបំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែន**បច្ចេក**ទេស ។

4 កិច្ចការពារ និងបង្ការជំងឺរាតត្បាតផ្សេងៗ ។

5 ការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់សារធាតុពុល ។

6 ការធ្វើកន្លែងទុកសំណល់រឹង ។

7 ការការពារការហូរច្រោះនៅកន្លែងកាយជញ្ជាំងភ្នំ និងកន្លែងចាក់សំណល់ដី និង ថ្មដោយ**ដាំ**ស្មៅ និងដើមឈើការពារ ។

8 ការកាត់បន្ថយភាពល្អក់នៅកន្លែងលាងថ្ម កន្លែងយកថ្ម និងកន្លែងរោងចក្រលាយ**បេតុង** ។

9 កិច្ចការជំរុញឱ្យមានការដាំដើមឈើ នៅទីសាធារណៈ ឬតំបន់ជុំវិញតំបន់ការពារទាំង**នោះ** ។

10 ការធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងបច្ចេក**ទេស**និងទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតម្រូវឱ្យធ្វើ ។

11 ការធ្វើការអភិរក្ស ប្រភេទសត្វព្រៃសំខាន់ៗដែលធ្លាប់មាននៅតំបន់គំរោង និងដំណើរ**ការស្ថា**នីយចិញ្ចឹមត្រី ។

Draft

12 ការធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីប្រភេទព្រៃឈើ និងពពួកសត្វព្រៃ ដែលត្រូវអភិរក្សក្នុងតំបន់គំរោង ។

13 ការធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំ វិធីសាស្ត្រការពារសុខភាព អនាម័យ-សុវត្ថិភាពការងារ ។

14 ការត្រៀមថវិកាបំរុងទុកសំរាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន និងការចំណាយលើថវិកានេះ ។

## ៩.៤ កម្មវិធីអង្កេតតាមដាន ត្រួតពិនិត្យការអនុវត្តវិធានការណ៍ការពារបរិស្ថាន

កម្មវិធីអង្កេតតាមដាន ត្រួតពិនិត្យការអនុវត្តវិធានការណ៍ការពារបរិស្ថាន (វិធានការកាត់បន្ថយការប៉ះពាល់បរិស្ថាន ដែលបានចែងក្នុងជំពូក ៧ និង៨ក្នុងការកំណត់ទំហំនៃការប៉ះពាល់អវិជ្ជមាន និង វិធានការកាត់បន្ថយ នេះ និងបញ្ជាក់អំពី កិច្ចការ ដែលត្រូវអង្កេតតាមដាន និងត្រួតពិនិត្យគំរោងផងដែរ ។ ម៉្យាងវិញទៀត កម្មវិធីនេះនឹងប្រមើលឃ្លាំមើលសកម្មភាពការអនុវត្តន៍ គំរោង ដោយម្ចាស់គំរោងនៅក្នុងគ្រប់ដំណាក់កាលគំរោង ។ កម្មវិធីនេះមានដូចតទៅ: (មានចែងក្នុងតារាង ៦៣ខាងក្រោម)

Draft

## តារាង ៦៣: ផែនការត្រួតពិនិត្យតាមដានបរិស្ថាន

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងខ្សែបញ្ជូនអគ្គិសនី | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ក. ធនធានរូបសាស្ត្រ | | | | |
| ១ | សណ្ឋានដី និង ឋានលេខា | - ពិនិត្យមើលការឈូសឆាយភ្នំកន្លែងយកថ្មតើបានធ្វើជើងទេរត្រឹមត្រូវ ដាំស្មៅ ឬរុក្ខជាតិ សំរាប់ការពារការហូរច្រោះឬទេ និងត្រួតពិនិត្យការពង្រាបដី ។<br>- ត្រួតពិនិត្យការពង្រាបដី នៅការដ្ឋានយកដី ថ្ម គ្រួស កន្លែងចោលសំណល់ដី និងថ្ម ពេលសាងសង់រួចមាន សំអាតធ្វើជើងទេរជញ្ជាំង និងដាំដើមឈើឡើងវិញនៅកន្លែងទាំងនោះឬទេ ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង ។ |
| ២ | ការហូរច្រោះ និង គុណភាពដី | - ពិនិត្យមើលការឈូសឆាយភ្នំ តើបានធ្វើជើងទេរត្រឹមត្រូវដាំស្មៅឬរុក្ខជាតិសំរាប់ការពារ ការហូរច្រោះហើយ តាមជញ្ជាំងទំនប់ និងមានធ្វើប្រឡាយ រួមទាំងរណ្តៅ សំរាប់ត្រង កករឬទេ ។<br>- ពិនិត្យមើលគុណភាពដីនៅខាងកន្លែងស្តុកសំភារៈ ស្តុកប្រេងឥន្ធនៈសារធាតុគីមី រោងជាងមានការសំអាត និងគ្រប់គ្រងត្រឹមត្រូវល្អ ឬទេ ។<br>- ពិនិត្យមើលការដាំកំរាលរុក្ខជាតិ ការពារការហូរច្រោះដី នៅកន្លែងចោលដីស្អុយឬសំណល់ថ្ម កន្លែងយកដី ថ្ម គ្រួស និងខ្សាច់ ។<br>- ពិនិត្យមើលកន្លែងចតគ្រឿងចក្រ និងកន្លែងស្តុកប្រេង និងសារធាតុគីមី (ការកំពប់លើដី) លើដីសារធាតុទាំងនេះលើដី) ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | |
| ៣ | ប្រពន្ធ័ជលសាស្ត្រ | - សង្កេត តាមដានមើលភាពប្រែប្រួលនៃស្ទឹង ព្រែក អូរនៅក្នុងតំបន់គំរោងទាំងមូល<br>- ត្រួតពិនិត្យមើលការបញ្ចេញទឹកទៅខាងក្រោមទំនប់ទី២មានចំនួនមិនតិចជាង ១.៥ម$^{៣}$/វិនាទី (នៅរដូវប្រាំង) មកខាងក្រោមដើម្បី រក្សាការពារជីវៈចំរុះនៃតំបន់អន្លង់ល្អាង ។<br>- ត្រួតពិនិត្យប្រព័ន្ធលូទឹកស្អុយដែលបង្ហូរចូលក្នុងអូរ-ស្ទឹង(យកទឹកទៅវិភាគនៅកន្លែងចំណុចប្រសព្វមាត់ហូរចេញពីអូរទៅស្ទឹងអាតៃនោះរួចពិនិត្យលទ្ធផលយោងតាម ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវៈចំរុះរបស់ក្រសួងបរិស្ថាន ឬទេ) ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើ ម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល៣ខែម្តង<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង់និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង ។ |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងខ្សែបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៤ | គុណភាពទឹក លើដី និង ក្រោមដី | - ពិនិត្យមើលបំរែបំរួលកម្រិតកំពស់ទឹកក្រោមដីនៅក្នុងតំបន់គំរោង ផ្តែកលើអណ្តូងក្រុមហ៊ុន និងនៅតំបនអូរសោម ។<br>- ត្រួតពិនិត្យកាកសំណល់រឹងរាវកន្លែងរស់នៅ និងការិយាល័យរបស់គំរោង និងពិនិត្យមើលកន្លែងចតគ្រឿងចក្រនិងកន្លែងស្តុកប្រេងនិងសារធាតុគីមី( ការកំពប់សារធាតុទាំងនេះ) ។ មានការលេចជ្រាបចូលប្រភពទឹកក្រោមដីដែរឬទេ?<br>- ពិនិត្យមើលគុណភាពទឹកតាមរយៈពិសោធន៍គុណភាពស្ទឹងអាតៃក្រោមអគារថាមពលទី២ និងក្នុងអាងទាំងពីរដោយបញ្ជាក់ថាគុណភាពយោងតាមស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវៈចំរុះ របស់ក្រសួងបរិស្ថាន ឬទេ? ។<br>- ធ្វើការតាមដានការកើតនូវរុក្ខជាតិទឹកចម្រៃដូចជា ចក កំផ្លោក ពើក សារាយ ។ល។ នៅក្នុងអាងទី១ និងទី២ ។<br>- ពិនិត្យកន្លែងដាំស្មៅតាមឫដើមឈើតាមទីជំរាល កន្លែងចាក់សំណល់ដីនិងថ្ម តើរុក្ខជាតិទាំងនេះដុះបានល្អឬទេ ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើ ម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង ។ |
| ៥ | ការបំពុលខ្យល់ | - ត្រួតពិនិត្យមើលគុណភាពខ្យល់ក្នុងតំបន់គំរោង ដូចជា ផង់ធូលី កន្លែងបំផ្ទុះ កន្លែងយកដី ជីកដី យកថ្ម ខ្សាច់ ភ្លើងឆេះព្រៃ ។ល។<br>- ត្រួតពិនិត្យមើលការបញ្ចេញផ្សែងរបស់គ្រឿងចក្រ ។<br>- ត្រួតពិនិត្យការគ្រប់គ្រងសំណល់រឹង-រាវរបស់ គំរោងមានភាយក្លិនមិនល្អឬទេ ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ<br>- រដ្ឋបាលព្រៃឈើ | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈ ពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិនិងថែទាំ គំរោង រយៈពេល ៣ខែម្តង ។ |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងបណ្តាញខ្សែបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៦ | ការបំពុលទឹក | - ត្រួតពិនិត្យព្រៃឈើកន្លែងដែលត្រូវលិច (មើលផែនទីទី២) បានកាប់សំអាត និងបានប្រមូលចេញពីតំបន់នោះស្អាតឬទេមុនពេលតម្កល់ទឹកក្នុងអាង ។<br>- ត្រួតពិនិត្យមើលការស្រង់ឈើដែលអណ្តែតទឹកចេញ តើបានស្អាតនិងត្រឹមត្រូវឬទេ?<br>- ត្រួតពិនិត្យការគ្រប់គ្រងសំណល់រឹង-រាវរបស់គំរោង ។<br>- ត្រួតពិនិត្យប្រព័ន្ធលូទឹកស្អុយដែលបង្ហូរចូលក្នុងអូរ-ស្ទឹង(យកទឹកទៅវិភាគនៅកន្លែងចំណុចប្រសព្វមាត់លូហូរធ្លាក់ក្នុងអូរ ឬស្ទឹងរួចពិនិត្យលទ្ធផលយោង តាមស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវៈចំរុះរបស់ក្រសួងបរិស្ថានឬទេ) ។<br>- ធ្វើការតាមដានការកើតនូវរុក្ខជាតិទឹកចង្រៃដូចជា ចក កំប្លោក ពើក សារាយ ។ល។ នៅក្នុងអាងទី១ និងទី២ ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិនិងថែទាំគំរោងរយៈពេល ៣ខែម្តង ។ |
| ៧ | ការបំពុលដី | - ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់ គំរោង ។<br>- ត្រួតពិនិត្យកន្លែងស្តុកប្រេងឥន្ធនៈ កន្លែងចតគ្រឿងចក្ររបស់គំរោង (ការកំពប់ប្រេង និងថ្នាំគីមីទៅលើដីក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងតាមគន្លងខ្សែបញ្ជូន) ។ | | |
| ៨ | សំលេង និង រំញ័រ | - ត្រួតពិនិត្យសំលេង និង រំញ័ររបស់រថយន្ត គ្រឿងចក្រ និងការបំផ្ទុះក្នុងតំបន់គំរោង<br>- ត្រួតពិនិត្យពេលវេលាធ្វើការរបស់គំរោង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងរយៈពេល ៣ខែម្តង ។ |
| ខ. ធនធានជីវសាស្ត្រ | | | | |

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងខ្សែបណ្តាញបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ១ | ធនធានព្រៃឈើ និង ជីវកសត្វ | - ត្រួតពិនិត្យមើលសកម្មភាពបរបាញ់សត្វ និង ចរាចរឈើ និង សត្វព្រៃរបស់បុគ្គលិក កម្មករ គំរោង និង អ្នកចំណូលថ្មី ។<br>- ត្រួតពិនិត្យសំលេងរបស់គ្រឿងចក្រ និងពេលវេលាធ្វើការ ។<br>- ត្រួតពិនិត្យការរានដីព្រៃឈើក្នុងតំបន់ការពារ និងអភិរក្សយកធ្វើកម្មសិទ្ធិខុសច្បាប់ ។<br>- ត្រួតពិនិត្យលើតំបន់ដែលត្រូវកាប់សំអាតព្រៃឈើនៅក្នុងអាងទាំង២នៅតាមខ្សែបណ្តាញបញ្ជូនចរន្ត តើមានការកាប់ឈើលើសពីតំបន់ព្រៃឈើផ្សេងទៀតឬទេ (ដោយប្រើGPS ផ្ទៀងផ្ទាត់ជាមួយចំណុចនិយាមការនៃតំបន់ទាំងនោះ) ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រដ្ឋបាលព្រៃឈើ<br>- អាជ្ញាធរដែនដី ពាក់ព័ន្ធ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំរយៈពេល ៣ ខែម្តង។ |
| ២ | ជីវសាស្ត្រ សត្វព្រៃ និង មច្ឆជាតិ | - ត្រួតពិនិត្យមើលសកម្មភាពបរបាញ់សត្វរបស់បុគ្គលិក គំរោង និងអ្នកចំណូលថ្មី ។<br>- ត្រួតពិនិត្យសំលេងរបស់គ្រឿងចក្រ ការបំផ្ទុះ និង ពេលវេលាធ្វើការ ។<br>- ត្រួតពិនិត្យ តាមដានប្រភេទ និងបរិមាណសត្វព្រៃ ត្រី ។<br>- ត្រួតពិនិត្យកន្លែងចញ្ចឹមត្រី ជិតដុតពូជ និងពិនិត្យកន្លែងដែលត្រូវព្រលែងចូលក្នុងតំបន់ក្បែរខាងមានលក្ខណៈជំរកធម្មជាតិប្រហែល ឬដូចដើមឬទេ ។<br>- ត្រួតពិនិត្យមើលមានការដាក់ផ្លាក ប៉ាន់ណូសេចក្តីជូនដំណឹងអំពីចំណីខ្សែភ្លើងនៅតាមផ្លូវចូលបានគ្រប់គ្រាន់ឬទេ? | | |
| **គ.** | **មធនធានសេដ្ឋកិច្ច និង សង្គម** | | | |
| ២ | ការរស់នៅ និង មុខរបររបស់សហគមន៍ មូលដ្ឋាន | - ត្រួតពិនិត្យការជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុន (ផ្តល់អាទិភាពឱ្យអ្នកភូមិជុំវិញតំបន់គំរោងទាំងស្រី ទាំងប្រុស) ។<br>- ត្រួតពិនិត្យតាមដានលើកម្រិតជីវភាពអ្នកនេសាទក្នុងតំបន់អាង និង ស្ទឹងអាតៃ មានការបាត់បង់ប្រាក់ចំណូល ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគំរោងនេះ ។<br>- ត្រួតពិនិត្យមើលតំបន់ទីកន្លែងគួរឱ្យព្រួយត្រូវបានកែលំអរ និងស្តារឡើងវិញដោយក្រុមហ៊ុនឬទេ ?<br>- ត្រួតពិនិត្យមើលមានការដាក់ផ្លាក ប៉ាន់ណូសេចក្តីជូនដំណឹងអំពីចំណីខ្សែភ្លើង នៅតាមផ្លូវចូលបានគ្រប់គ្រាន់ឬទេ? | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- អាជ្ញាធរដែនដីពាក់ព័ន្ធ | - ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំ គំរោង រយៈពេល ៣ខែម្តង ។ |



Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់បង្ហាចនាសម្ព័ន្ធគំរោង និងប្រព័ន្ធខ្សែបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៣ | ប្រពៃណី វប្បធម៌ និងសាសនា | - ពិនិត្យតាមដានរាល់ការខុសឆ្គង និងអំពើល្មើសរបស់បុគ្គលិកក្រុមហ៊ុន ទៅលើ ប្រពៃណី ទំនៀមទំលាប់ និងវប្បធម៌របស់ប្រទេសជាតិ និងរបស់ប្រជាជនមូលដ្ឋាន ។<br>- ពិនិត្យតាមដាន ទំនាស់ប្រកាន់ពូជសាសន៍ រវៀងកម្មករ ខ្មែរ និង ចិន | | |
| ៤ | ផ្លូវគមនាគមន៍ និងចរាចរ | - ត្រួតពិនិត្យការធ្វើចរាចរណ៍ និង ផ្លាកសញ្ញាល្បឿន តាមផ្លូវក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការថែទាំជួសជុលផ្លូវក្នុងតំបន់គំរោង ។<br>- ពិនិត្យការថែទាំផ្លូវ និងចរាចរណ៍នៃតំបន់ទេសចរណ៍ថ្មី ក្នុងតំបន់អាង ឬតំបន់ ក្បែរខាង (ប្រសិនបើមាន) ។<br>- ត្រួតពិនិត្យសំលេង និង រំញ័ររបស់រថយន្ត គ្រឿងចក្រ ក្នុងតំបន់គំរោង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- មន្ទីរសាធារណការខេត្តពាក់ព័ន្ធ<br>- មន្ទីរទេសចរណ៍ខេត្តពាក់ព័ន្ធ<br>- អាជ្ញាធរដែនដីពាក់ព័ន្ធ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងរយៈ ពេល ៣ខែម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈ ពេល ៣ ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំ គំរោងរយៈពេល ៣ខែម្តង ។ |
| ៥ | សុខភាពសាធារណៈ | - ត្រួតពិនិត្យការថែរក្សាសុវត្ថិភាពនៅក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការថែទាំសុខភាពរបស់បុគ្គលិកកម្មករគំរោង ។<br>- ត្រួតពិនិត្យមើលបរិក្ខារ និងថ្នាំពេទ្យ ។<br>- ត្រួតពិនិត្យលើការទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការធ្វើចរាចរ និង ផ្លាកសញ្ញាល្បឿន តាមផ្លូវក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការដោះសំអាតគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះពីតំបន់គំរោង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- មន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ<br>- អាជ្ញាធរដែនដី<br>- មន្ទីរសាធារណការខេត្តពាក់ព័ន្ធ | |
| ៦ | ហានិភ័យ | - ត្រួតពិនិត្យការមើលតើមានការសិក្សាជាប្រចាំនូវទឹកក្រោមដី និងការលេចជ្រាប នៅតំបន់ជើងភ្នំក្រោមទំនប់ទី២ និងនៅតំបន់ទំនប់ទី១ដែរឬទេ ?<br>- ពិនិត្យតាមដានរាល់ហេតុការណ៍ ដែលអាចឱ្យមានការបាក់ទំនប់បាក់ភ្នំ ។<br>- **ត្រួតពិនិត្យការថែរក្សា សន្តិសុខ និង សុវត្ថិភាព លើជាតិផ្ទុះ ជាតិឆេះ ។**<br>- ពិនិត្យ និងទប់ស្កាត់ភ្លើងឆេះព្រៃ និងអំពើភេរវកម្ម ក្នុងតំបន់គំរោង ។ | - ក្រុមហ៊ុន<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ<br>- រដ្ឋបាលព្រៃឈើ | - ក្នុងអំឡុងពេលសាងសង់គំរោង រយៈ ពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំ គំរោងរយៈពេល៣ខែម្តង ។ |

## ៩.៥ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបំពាក់បំប៉នក៏ជាកត្តាសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ ដែលគំរោងត្រូវយកចិត្តទុកដាក់ ដើម្បីអនុវត្តន៏ផែនការរបស់គំរោងឱ្យបានជោគជ័យ។ ដើម្បីធ្វើឱ្យគំរោងនេះ មានការអភិវឌ្ឍប្រកបដោយចេរភាពចាំបាច់ត្រូវមាន ធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំពេញការងារឱ្យបានរីកចំរើន និងសុក្រឹត្យត្រឹមត្រូវទាំងការងារបច្ចេកទេស និងការងារបរិស្ថាន ដូច្នេះម្ចាស់គំរោងនឹងរៀបចំឱ្យមានវគ្គអប់រំបំពាក់បំប៉នដល់បុគ្គលិក និងកម្មករ ជាពិសេសបុគ្គលិក-កម្មករកម្ពុជាដូចជា: ចំណេះដឹងបច្ចេកទេសសំរាប់ប្រើប្រាស់បញ្ជាគ្រឿងម៉ាស៊ីនគ្រប់ប្រភេទក្នុងពេលសាងសង់ និងដំណើរការគំរោង។ ចំណេះដឹងពីការការពារសុវត្ថិភាពជាចំបងពេលកំពុងបំពេញការងាររបស់គំរោង។ បំពាក់បំប៉ន និងផ្សព្វផ្សាយពីជំនាញបច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធការបង្កឱ្យមានគ្រោះថ្នាក់ជាយថាហេតុពីសកម្មភាពគំរោងទៅលើធនធានធម្មជាតិ និងសង្គម ។ អប់រំនិងផ្សព្វផ្សាយវិធីសាស្ត្រការពារជំងឺរាតត្បាតផ្សេងៗ ជាពិសេសជំងឺអេសដីជាដើម។ បំពាក់បំប៉នដល់បុគ្គលិក-កម្មករក្នុងការគ្រប់គ្រងសំណល់រឹង-រាវ និងអប់រំបំពាក់បំប៉នបុគ្គលិកក្នុងការប្រើប្រាស់ និងថែទាំប្រព័ន្ធអាងប្រព្រឹត្ត កម្មសំណល់រាវ។ អប់រំពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗ ដែលមាននៅក្នុងតំបន់សំរាប់តម្រូវការសង្គមដូចជា ទឹក ដី ខ្យល់ ព្រៃឈើ សត្វព្រៃ ជាពិសេសធនធានធម្មជាតិនៃតំបន់ការពារ និងព្រៃការពារ ។ល។ អប់រំ ពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង-ជុំវិញតំបន់គំរោង និងចំណេះដឹងពីការអង្កេតតាមដានគំរោង ដែលទាក់ទងទៅនឹងបរិមាណ និងគុណភាពបរិស្ថានមានស្រាប់ ដែលត្រូវរងការប៉ះពាល់ដោយសារសកម្មភាពគំរោងនេះ។ អប់រំដល់កម្មករក្នុង ការគ្រប់គ្រងវត្ថុធាតុដើម ដែលជាសារធាតុ គីមីសំរាប់ប្រើប្រាស់ក្នុងរោងចក្រផលិតកម្មរបស់គំរោង។ ក្រុមហ៊ុនត្រូវជ្រើសរើសបុគ្គលិកដែលមានសមត្ថ ភាពខ្ពស់នៅប្រទេសចិនមក ជួយបង្ហាត់បង្រៀនដល់បុគ្គលិក-កម្មករគំរោង និងទទួលបន្ទុកចំណេះយ៉ាងស្រុង។ ក្រុមហ៊ុនត្រូវផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងប្រទេសចិន និងកម្ពុជាដោយបញ្ជូនគណៈប្រតិភូទៅទស្សនកិច្ចសិក្សា និងកម្មសិក្សានៅប្រទេសចិន។

Draft

## ៩.៦ ការប៉ាន់ប្រមាណថវិកាសំរាប់កិច្ចការពារបរិស្ថាន

ការការពារបរិស្ថានក្នុងតំបន់គំរោង និងជុំវិញតំបន់គំរោង គឺមានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យដំណើរការគំរោងមាននិរន្តរភាព។ ផ្អែកតាមផែនការនៃការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន និងផែនការត្រួតពិនិត្យ អង្កេតបរិស្ថានរបស់គណៈកម្មការចំរុះរបស់រាជរដ្ឋាភិបាលកម្ពុជានោះក្រុមហ៊ុនបានត្រៀមថវិកាចំណាយសំរាប់កិច្ចការពារត្រួតពិនិត្យ និងអង្កេតបរិស្ថានសរុបចំនួន ៣.០៩១.២៥០ដុល្លារអាមេរិក( បីលាន កៅសិបមួយពាន់ពីររយហាសិបដុល្លារអាមេរិក) ដូចមានរៀបរាប់លំអិតខាងក្នុងតារាងក្រោម:

**តារាង ៦៤: ការប៉ាន់ប្រមាណថវិកាសំរាប់កិច្ចការពារបរិស្ថានដោយក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd.**

| # | Item | Construction Period | O & M Period | Total Cost ($US) | Remarks |
|---|---|---|---|---|---|
| I | Construction area | | | | |
| *i* | *Water and soil protection* | | | | |
| 1 | Engineering measure | 500,000.00 | | 500,000.00 | Fuel, chemical storage, workshop, erosion protection etc... |
| 2 | Plant measure | 60,000.00 | 25,000.00 | 85,000.00 | Fire fighting system construction etc... |
| 3 | Temporary measure | 1,000,000.00 | | 1,000,000.00 | During Construction phase of Project: Latrine, Dumping site, medical supply, wells water supply, security guard, camps etc... |
| 4 | Floating debris | | 15,000.00 | 15,000.00 | Ferry and boats renting and cleaning debris |
| 5 | Water Quality Monitoring | | 18,188.00 | 18,188.00 | |
| 6 | Waste water dispose | 52900 | 150,000.00 | 202,900.00 | O & M cost/ Year of $5000) for 30 Years and cost for wastewater treatment unit at the living areas |
| 7 | Sanitary waste | 48160 | 108,000.00 | 156,160.00 | (O&M Cost/ Year of 3600) for 30 Years included construction of adumping site |
| *ii* | *Atmosphere environment protection* | | | | |
| 1 | Water spray for dust removal | 20,000.00 | | 20,000.00 | During Construction phase of Project |
| 2 | Sanitary landfill | 15,200.00 | | 15,200.00 | 30 years |
| *iii* | *Wildlife protection* | | | | |

| # | Item | Construction Period | O & M Period | Total Cost ($US) | Remarks |
|---|---|---|---|---|---|
| 1 | Bio-Aquatic Protection | | 214,000.00 | 214,000.00 | For 5 years period<br>Fish hatchery cost: $50000, 2 Staffes & 5 inspectors: $69000($230/person-month), Fisheries Community: $95000 |
| 2 | Animal Protection | | 331,200.00 | 331,200.00 | For 6 years period<br>11 Samkos rangers : $151800, 9 Cardamom rangers: $124200 ($230/person-month) |
| *iv* | ***Forest-wildlife habitat protection*** | | | | |
| 1 | Samkos forest protection communities | | 20,000.00 | 20,000.00 | For 5 years period<br>$20000 |
| 2 | Cardamom forest protection communities | | 20,000.00 | 20,000.00 | For 5 years period<br>$20000 |
| *v* | ***Healthing protection*** | 40,000.00 | 26,400.00 | 66,400.00 | Health Insurance for Cambodian Labors |
| *vi* | ***Evironmental Education*** | | 50,000.00 | 50,000.00 | Cover 5 years |
| *vii* | ***Cosultation Fee*** | 50,000.00 | 50,000.00 | 100,000.00 | Consultations fee during costruction and o&M Phase |
| | ***Total*** | 1,236,260.00 | 977,788.00 | 2,814,048.00 | |
| **II Resettlement Cost and other compensations** | | | | 130,000.00 | The company will prepare resettlement plan and other compensations |
| **Contingency** | | | | 147,202.00 | |
| **Grand Total** | | | | 3,091,250.00 | |